## ក្រដាសចម្លើយជំពូកទីមួយ

សូមបំពេញចន្លោះខាងក្រោម៖

ឈ្មោះ………………………………………………………………………………………………………

លេខរៀងសិស្ស…………………………………………………………………………………………

(ទុកចន្លោះចោលប្រសិនជាអ្នកមិនស្គាល់លេខរបស់អ្នក។)

អាសយដ្ឋាន……………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

ប្រទេស………………………………………………………………………………………………

## ការណែនាំ

ពេលអ្នកបានបញ្ចប់ការសិក្សាជំពូកនីមួយៗ សូមបំពេញក្រដាសចម្លើយការវាយតម្លៃតាមជំពូក។ សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយមួយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។ ចូរដាក់ពណ៌ខ្មៅ សម្រាប់ចម្លើយដែលអ្នកបានជ្រើសរើស។ *សូមប្រាកដថា លេខដែលនៅលើក្រដាសចម្លើយ គឺដូចគ្នានឹងលេខនៃសំណួរដែលអ្នកកំពុងតែឆ្លើយ។*

*ឧទាហរណ៏*

១. ការកើតជាថ្មីមានន័យថា

ក) នៅវ័យក្មេង។

ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។

គ) ចាប់ផ្តើមឆ្នាំថ្មី។

ចម្លើយត្រឹមត្រូវគឺ **ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។** ដូច្នេះ អ្នកគួរតែដាក់ពណ៌ខ្មៅ ⓑ ដូចនេះ៖

១. (ក) ● (គ) (ឃ)

*សូមបើកទំព័របន្ទាប់មួយទៀត នៅពេលអ្នកចង់ចាប់ផ្តើម។*

# ក្រដាសចម្លើយជំពូកទីមួយ

សូមដាក់ពណ៌ខ្មៅ នៅកន្លែងដែលត្រឹមត្រូវដោយប្រុងប្រយ័ត្ន សម្រាប់លេខនីមួយៗ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១. | ក | ខ | គ | ឃ | ១១. | ក | ខ | គ | ឃ |
| ២. | ក | ខ | គ | ឃ | ១២. | ក | ខ | គ | ឃ |
| ៣. | ក | ខ | គ | ឃ | ១៣. | ក | ខ | គ | ឃ |
| ៤. | ក | ខ | គ | ឃ | ១៤. | ក | ខ | គ | ឃ |
| ៥. | ក | ខ | គ | ឃ | ១៥. | ក | ខ | គ | ឃ |
| ៦. | ក | ខ | គ | ឃ | ១៦. | ក | ខ | គ | ឃ |
| ៧. | ក | ខ | គ | ឃ | ១៧. | ក | ខ | គ | ឃ |
| ៨. | ក | ខ | គ | ឃ | ១៨. | ក | ខ | គ | ឃ |
| ៩. | ក | ខ | គ | ឃ | ១៩. | ក | ខ | គ | ឃ |
| ១០. | ក | ខ | គ | ឃ | ២០. | ក | ខ | គ | ឃ |

នេះជាការបញ្ចប់នៃតម្រូវការសម្រាប់ជំពូកទី១។ សម្រាប់ពិន្ទុ សូមផ្ញើក្រដាសចម្លើយជំពូកទី១ ទៅឱ្យគ្រូរបស់អ្នក ឬក៏ ទៅការិយាល័យដែលនៅក្នុងតំបន់របស់អ្នក។ សូមបន្តការសិក្សារបស់អ្នកនៅជំពូកទី២។

សម្រាប់ប្រើនៅការិយាល័យនៃសកល
វិទ្យាល័យ គ្លូបល ប៉ុណ្ណោះ

ថ្ងៃទី………………………………………………

ពិន្ទុ……………………………………………

PN 06.13

## ការវាយតម្លៃជំពូកទី១

១ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់សិស្សរបស់ព្រះអង្គថា ព្រះអង្គនឹងយាងត្រឡប់ទៅស្ថានបរមសុខវិញ និងចាត់មិត្ត សម្លាញ់ និងអ្នកដ៏ជាជំនួយការពារម្នាក់ទៀតដែលអាច

ក) គង់នៅជាមួយពួកគេទាំងអស់គ្នាក្នុងពេលតែមួយ ទោះបីពួកគេនៅកន្លែងណាក៏ដោយ។

ខ) ធ្វើការអស្ចារ្យជាងព្រះយេស៊ូទៅទៀត។

គ) មានប្រាជ្ញា ខ្លាំង និងប្រសើរជាង។

២ ពាក្យក្រិកប៉ារ៉ាក្លិតមានអត្ថន័យថាម្នាក់

ក) ដែលត្រាស់ហៅមកនៅក្បែរដើម្បីជួយ។

ខ) ដែលប្រទានជីវិត។

គ) ដែលប្រទានប្រាជ្ញា។

៣ ស្របតាមកណ្ឌគម្ពីររ៉ូម ៨:៥, ៦ គំនិតដែលត្រួតត្រាដោយព្រះវិញ្ញាណនាំមកនូវ

ក) ជំនឿ។

ខ) ជីវិត និង សេចក្ដីសុខសាន្ត។

គ) ព្រះអំណោយទានខាងវិញ្ញាណ។

៤ វិសុទ្ធមានន័យថាញែកចេញពី

ក) សកម្មភាពប្រចាំថ្ងៃរបស់ជីវិត។

ខ) មនុស្សដទៃផ្សេងទៀត។

គ) អំពើបាប និងថ្វាយជីវិតដល់ព្រះជាម្ចាស់។

៥ ជាព្រះវិញ្ញាណនៃសេចក្ដីពិត ព្រះវិញ្ញាណដ៏វិសុទ្ធនឹង

ក) ផ្ដល់ភាពជោគជ័យដល់អ្នកក្នុងការងារ។

ខ) ដករាល់បញ្ហាទាំងអស់ចេញពីជីវិតរបស់អ្នក។

គ) ជួយអ្នកឱ្យយល់អំពីព្រះគម្ពីរ។

៦ នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ និងបង្ហាញអ្នកអ្វីដែលល្អបំផុតសម្រាប់អ្នក ព្រះអង្គកំពុងដើរតួជា

ក) ព្រះវិញ្ញាណនៃសេចក្ដីពិត។

ខ) ព្រះវិញ្ញាណនៃប្រាជ្ញាញាណ។

គ) ព្រះវិញ្ញាណនៃព្រះបន្ទូលសន្យា។

៧ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកថ្វាយសិរីរុងរឿងដល់

ក) ព្រះអង្គផ្ទាល់។

ខ) ព្រះយេស៊ូ។

គ) ក្រុមជំនុំ។

៨ ខារីស្មាមានន័យថា

ក) ការកែប្រែចិត្តជឿ។

ខ) សមត្ថភាពមនុស្ស។

គ) ព្រះអំណោយទានដ៏អស្ចារ្យ។

៩ ព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងឱ្យស្រឡាញ់

ក) គ្រួសារ មិត្តសម្លាញ់ គ្រិស្តបរិស័ទឯទៀត និងសត្រូវរបស់យើងផងដែរ។

ខ) អស់អ្នកណាដែលចូលរួមក្រុមជំនុំរបស់យើង។

គ) របៀបរស់នៅចាស់របស់យើង។

១០ គោលបំណងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជា*ព្រះវិញ្ញាណនៃជីវិត*

ក) ផ្តល់ឱ្យអ្នកនូវគោលបំណងថ្មីសម្រាប់ការរស់នៅ។

ខ) មិនមានឥទ្ធិពលលើការជំរុញចិត្តរបស់យើងទេ។

គ) ចង់ឱ្យអ្នកស្លាប់ និងទៅស្ថានបរមសុខ។

១១ នៅពេលព្រះវិញ្ញាណនៃជីវិតប្រោសយើងឱ្យរួចពីសេចក្តីស្លាប់ យើងនឹង

ក) គ្មានរូបកាយទាល់តែសោះ។

ខ) មានរូបកាយផ្លាស់ប្តូររួចចេញពីភាពកម្សោយ។

គ) មានរូបកាយដូចគ្នាជាមួយដែនកំណត់ដូចគ្នា។

១២ គ្មាននរណាម្នាក់អាចក្លាយជាកូនរបស់ព្រះជាម្ចាស់ ឬ ទៅស្ថានបរមសុខ ដោយគ្មាន

ក) ការប្តេជ្ញាចិត្ត។

ខ) ការកែប្រែចិត្តជឿព្រះយេស៊ូ។

គ) ការមានព្រះជន្មរស់ឡើងវិញ។

១៣ ក្នុង………………………..ព្រះវិញ្ញាណដ៏វិសុទ្ធនាំអ្នកទៅរកព្រះគ្រិស្ត បំបាក់អំណាចនៃអំពើបាបដែលត្រួតត្រាអ្នក និង យាងមកគង់ក្នុងអ្នក។

ក) ការមានព្រះជន្មរស់ឡើងវិញ។

ខ) ការកែប្រែចិត្តជឿ។

គ) ពិធីលៀងព្រះអម្ចាស់។

១៤ អ្នកអាចមានគោលបំណងក្នុងជីវិតតាមរយៈ

ក) អនុញ្ញាតឱ្យព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំអ្នក។

ខ) ការបង្កើតគោលដៅ។

គ) ការផ្តោតលើការបំពេញសេចក្តីត្រូវការ។

១៥ យើងអាចជួយជំរុញការថ្វាយបង្គំរបស់យើងតាមរយៈការចំណាយពេលច្រើន

ក) ដោយការទូលសូមអ្វីមួយ។

ខ) ដោយការនិយាយសេចក្តីអធិស្ឋានដូចគ្នាជារៀងរាល់ថ្ងៃ។

គ) ដោយការច្រៀង និង សរសើរតម្កើងព្រះអម្ចាស់។

១៦ កណ្ឌគម្ពីរទំនុកតម្កើង ១៤៥ ប្រាប់អំពី

ក) ភាពអស្ចារ្យរបស់ព្រះជាម្ចាស់។

ខ) សារៈសំខាន់នៃការអធិស្ឋាន។

គ) គោលបំណងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១៧ ការអានកណ្ឌគម្ពីរទំនុកតម្កើងជារៀងរាល់ថ្ងៃនឹងជួយអ្នក

ក) គិតអំពីការជួយអ្នកដទៃ។

ខ) សរសើរតម្កើងព្រះជាម្ចាស់កាន់តែខ្លាំងឡើង។

គ) ទុកចិត្តលើពិធីបុណ្យខាងក្រៅ។

១៨ ព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកដកនូវឧបសគ្គរាំងចំពោះការអធិស្ឋានរបស់អ្នក ដោយជួយអ្នក

ក) បំភ្លេចអំពើបាបរបស់អ្នក។

ខ) ពិភាក្សាអំពើបាបរបស់អ្នកជាមួយអ្នកដទៃ។

គ) សារភាពបាបរបស់អ្នកទៅកាន់ព្រះជាម្ចាស់។

១៩ ក្លសសូឡាលៀមានន័យថា

ក) ការអធិស្ឋាន ឬ និយាយជាភាសាដទៃ។

ខ) ព្រះអំណោយទាននៃការសង្គ្រោះ។

គ) ការជ្រមុជទឹក។

២០ កណ្ឌគម្ពីរភីលីព ៤:៦ ប្រាប់យើងឱ្យ

ក) ខ្វល់ខ្វាយអំពីអំពើបាបរបស់យើង។

ខ) តែងតែអធិស្ឋានជាភាសាដទៃ។

គ) ទូលសូមព្រះជាម្ចាស់អំពីសេចក្ដីត្រូវការរបស់យើង។

នេះជាការបញ្ចប់នៃលក្ខណ្ឌសម្រាប់ជំពូកទីមួយ ។ សូមបញ្ចប់នៅត្រង់នេះ ហើយប្រគល់ក្រដាសចម្លើយរបស់អ្នកសម្រាប់ជំពូកមួយដល់គ្រូបង្រៀនរបស់អ្នក។ ចូរបន្តការសិក្សារបស់អ្នកក្នុងជំពូកទីពីរ។